ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង

## ស្តីអំពីពិព័រណ៍ការងារ និងផលិតភាពជាតិ លើកទី៩ ឆ្នាំ២០១៩
## ថ្ងៃទី០២ ដល់ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩
## នៅអគារពាណិជ្ជកម្ម និងពិព័រណ៍កោះពេជ្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដល់ក្រសួង ស្ថាប័ន និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល អ្នកស្វែងរកការងារធ្វើ សិស្ស និស្សិត ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និងសាធារណជន មេត្តាជ្រាបថា **ពិព័រណ៍ការងារ និងផលិតភាពជាតិ លើកទី៩** នឹងត្រូវបានរៀបចំចាប់ពីថ្ងៃទី០២ ដល់ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩ ពីម៉ោង ០៨:០០ នាទីព្រឹក ដល់ម៉ោង ២០:០០ នាទីយប់ នៅអគារពាណិជ្ជកម្ម និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ ក្រោមកិច្ចសហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជារាជធានីភ្នំពេញ (ស.ស.យ.ក) សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) និងគាំទ្រដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)។ ព្រឹត្តិការណ៍ការងារដ៏ធំជាងគេបំផុតនៅកម្ពុជាលើកទី៩នេះ រៀបចំឡើងក្នុងគោលបំណងដើម្បី៖

- បង្កើតជាវេទិកាការងារដ៏ធំនៅមួយកន្លែងដោយងាយស្រួល សម្រាប់និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល និងអ្នកស្វែងរកការងារធ្វើ ដើម្បីតាំងបង្ហាញ ធ្វើការផ្លាស់ប្តូរ និងចែករំលែកព័ត៌មានទីផ្សារការងារ។
- និយោជកអាចផ្សព្វផ្សាយពីតម្រូវការជ្រើសរើសកម្លាំងពលកម្មនាពេលបច្ចុប្បន្ន និងអនាគត ដើម្បីទាក់ទាញអ្នកស្វែងរកការងារធ្វើដែលមានសមត្ថភាព។
- អ្នកស្វែងរកការងារធ្វើអាចដាក់ពាក្យ និងសម្ភាសការងារនៅនឹងកន្លែងផ្ទាល់ ព្រមទាំងទទួលបានព័ត៌មានអំពីឱកាសការងារ និងឱកាសក្នុងការអភិវឌ្ឍជំនាញនានា។
- អ្នកផ្តល់ការអប់រំបណ្តុះបណ្តាលអាចផ្សព្វផ្សាយកម្មវិធីសិក្សា វគ្គសិក្សា និងកម្មវិធីអភិវឌ្ឍជំនាញគ្រប់ប្រភេទ។
- លើកកម្ពស់ការយល់ដឹង និងបណ្តុះគំនិតអំពីការបង្កើនផលិតភាពតាមរយៈការបង្ហាញគំនិត បទពិសោធន៍ ជំនាញ បច្ចេកវិទ្យា និងការអនុវត្តល្អសម្រាប់លើកកម្ពស់ផលិតភាព ប្រសិទ្ធភាពក្នុងការងារដោយវាគ្មិនជាតិ-អន្តរជាតិល្បីៗ។
- បង្ហាញបេក្ខភាពជ័យលាភីក្នុងការប្រកួតប្រជែងកម្មករនិយោជិតឆ្នើម និងរោងចក្រស្អាត (5S)។
- បង្កើតវេទិកាសម្រាប់ពង្រីកបណ្តាញទំនាក់ទំនងផ្នែកធនធានមនុស្ស (HR Networking)។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រប់ក្រសួង ស្ថាប័ន និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ អ្នកស្វែងរកការងារធ្វើ និងសាធារណជន ដែលមានបំណងចូលរួមតាំងបង្ហាញស្លាកសញ្ញា ឱកាសការងារ ជ្រើសរើសកម្លាំងពលកម្ម និងស្វែងរកការទាក់ទងសួរព័ត៌មានលម្អិតអំពីព្រឹត្តិការណ៍ពិព័រណ៍ការងារខាងលើនេះតាមរយៈទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខទូរស័ព្ទ **០១៧ ៨៧១ ៨០៧** ឬចូលមើលគេហទំព័រ **www.event.nea.gov.kh**។

ថ្ងៃ ចន្ទ ១២កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែសីហា ឆ្នាំ២០១៩

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩